**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ៧៣៨/២១ ក.ប/ខ.ល

## សារលិខិតជូនពរ

**សូមគោរពជូន សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា**
**ក្នុងឱកាសទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២១**

*ជាទីគោរពដ៏ខ្ពង់ខ្ពស់ !*

ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១១០ នៃទិវាអន្តរជាតិនារី ០៨ មីនា ឆ្នាំ២០២១ នេះ ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ យើងខ្ញុំសូមប្រសិទ្ធពរបវរមហាប្រសើរជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** សូមសម្តេចទទួលបាននូវកម្លាំងខ្លាំងក្លាប្រាជ្ញាឈ្លាសវៃ ជន្មាយុយឺនយូរ និងសម្រេចជោគជ័យដ៏ត្រចះត្រចង់ថ្មីៗបន្ថែមទៀត ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមរបស់សម្តេចចំពោះប្រជាជន និងប្រទេសជាតិ។

ក្នុងឱកាសដ៏មហាកិត្តិយសនេះ យើងខ្ញុំទាំងអស់គ្នា សូមកោតសរសើរដ៏ស្មោះចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលជាកុលធីតាខ្មែរដ៏ឆ្នើមមួយរូប ជាឧត្តមភរិយា **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដ៏ប្រពៃ ជាមាតាដ៏ល្អ ជាជីដូនដែលមានព្រហ្មវិហារធម៌មានស្នាដៃដ៏ប៉ិនប្រសប់ និងគំនិតប្រាជ្ញាដ៏ឧត្តុង្គឧត្តមឈ្លាសវៃ ក្នុងការដឹកនាំកាកបាទក្រហមកម្ពុជា ដើម្បីបំពេញបេសកកម្មមនុស្សធម៌ដ៏ថ្លៃថ្លាប្រកបដោយគុណធម៌ សប្បុរសធម៌ និងបានចលនាភរិយាថ្នាក់ដឹកនាំជាច្រើនរូបទៀត រួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការយកចិត្តទុកដាក់ដោះស្រាយទុក្ខលំបាកជូនប្រជាពលរដ្ឋរងគ្រោះគ្រប់រូប គ្រប់ទីកន្លែងនៅទូទាំងប្រទេស និងបានខិតខំលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងតម្លៃគ្រួសារខ្មែរឱ្យបានខ្ពង់ខ្ពស់រុងរឿង។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលជាភរិយាដ៏ឧត្តុង្គឧត្តម នៃ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងបុត្រា-បុត្រី ចៅប្រុស-ចៅស្រីទាំងអស់ ទទួលបាននូវពរជ័យបវរសួស្តី សិរីមង្គល វិបុលសុខគ្រប់ប្រការ និងសូមប្រកបតែសុខភាពល្អបរិបូរណ៍ អាយុយឺនយូរ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បីដឹកនាំកាកបាទក្រហមកម្ពុជា ទទួលបានជោគជ័យត្រចះត្រចង់ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំទាំងអស់គ្នា។

*ថ្ងៃ សុក្រ ៧ រោច ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*

*នៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មីនា ឆ្នាំ២០២១*

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩*